**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១២១២ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃ នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

*** ៚ ***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃនាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួន ពីរ (០២) ដូចខាងក្រោម :

- ការិយាល័យគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ច ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំ និងចាត់ចែងការងារបណ្តុះបណ្តាលមន្ត្រីរាជការគយ និងរដ្ឋាករ។
- រៀបចំគ្រប់គ្រងស្ថិតិលើទិន្នន័យបុគ្គលិក និងតារាងព័ត៌មាន សកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយ និងរដ្ឋាករ។
- ចូលរួមរៀបចំការងារផ្លាស់ប្តូរ ផ្ទេរភារកិច្ច តម្លើងឋានៈ ឬបន្ថយឋានៈចំពោះមន្ត្រីរាជការគយ និងរដ្ឋាករ ក្រោមនិវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- រៀបចំបៀវត្សន៍ ក្របខ័ណ្ឌ ប្រាក់កំរៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារ និងគ្រប់គ្រងគោលនយោបាយធានារ៉ាប់រងសង្គម និងរបបសំរាកលំហែ។
- គ្រប់គ្រងការចេញលិខិតឧទ្ទេសនាម ឬលិខិតបញ្ជាបេសកកម្មរបស់មន្ត្រីរាជការគយនិងរដ្ឋាករ។
- ចូលរួមរៀបចំគោលនយោបាយ លើកសរសើរ ផ្តល់កិត្តិយស ដាក់វិន័យ ស្តីបន្ទោស ឬព្រមានដល់មន្ត្រីគយ និងរដ្ឋាករ ដោយផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមាននានា។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ/កម្ពុជា។

- ចាត់ចែង និងសហការរៀបចំទិវាបុណ្យជាតិ និងអន្តរជាតិនានា និងពិធីចាំបាច់ផ្សេងៗក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- គ្រប់គ្រងស្ថិតិ ការប្រើប្រាស់អាវុធរបស់អង្គភាព។
- ចាត់ចែង រៀបចំ និងត្រួតពិនិត្យនូវការគោរពវិន័យការងារ ការថែរក្សាសណ្តាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាទាំងមូល។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៤.-**

ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- ចូលរួមលើកគម្រោងផែនការប្រមូលចំណូលពន្ធ អាករគ្រប់ប្រភេទ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងតាមដានរំលឹកអំពីការប្រតិបត្តិ។
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា នីតិវិធីនានា បំរើឱ្យការងារគណនេយ្យពន្ធគយ។
- គ្រប់គ្រងបញ្ជីស្លាកពាក់ព័ន្ធនឹងប្រាក់ពន្ធលើទំនិញនាំចេញ នាំចូល ប្រាក់ផាកពិន័យ ប្រាក់រង្វាន់ ប្រាក់បំណុល ប្រាក់បៀវត្សន៍ និងរាល់ចំណូលផ្សេងៗទៀតដែលមាន។
- គ្រប់គ្រងការងារហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាជារួម ជាពិសេសតាមរយៈការប្រមូលផ្តុំតម្រូវការ និងធ្វើកម្មវិធីចំណាយរបស់អង្គភាពឱ្យបានទៀងទាត់ ដោយត្រូវគ្រប់គ្រងការធ្វើរបាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែ និងធ្វើរបាយការណ៍សម្រេចទូទាត់ចំណូល ចំណាយថវិកាប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- គ្រប់គ្រងការទិញ ការបែងចែកមធ្យោបាយ សម្ភារបរិក្ខារនានាសំរាប់បំរើការងាររបស់អង្គភាព។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សម្ភារ ធ្វើបញ្ជីសារពើភ័ណ្ឌ និងគ្រប់គ្រងការប្រើប្រាស់អាគារ ការរៀបចំជួសជុលផ្សេងៗរបស់អង្គភាព។
- តាមដាន រំលឹក ការគ្រប់គ្រងគណនីពិសេស។
- កាន់កាប់រាល់សាលាកប័ត្រ និងបញ្ជីគណនេយ្យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- បោះពុម្ពបង្កាន់ដៃពន្ធ ឯកសារបច្ចេកទេស បញ្ជីគណនេយ្យ ឯកសាររដ្ឋបាល តែមប្រើលតាប័ត្រយានយន្ត និងឯកសារនានា ដែលទាក់ទងនឹងការងារគយ និងរដ្ឋាករ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៥.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

~ // 

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្ត តាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ /

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**<u>ចម្លងជូន</u> :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត- ក្រុងដែលពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ